រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខៈ.........................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី......ខែធ្នូ ឆ្នាំ២០១៥

**ជម្រាបជូន**
**ឯកឧត្តមអភិបាលខេត្តបាត់ដំបង កំពង់ចាម កំពត និងខេត្តសៀមរាប**

**កម្មវត្ថុ** ៖ សំណើសុំចាត់បញ្ជូនឯកឧត្តមអភិបាលរងមួយរូប ទទួលបន្ទុកការងារព័ត៌មាន ឲ្យចូលជាសមាជិកក្រុមពិគ្រោះយោបល់សម្រាប់គម្រោងជំនួយប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ដំណាក់កាលទី២ ( Cambodia Communication Assistance Project Phase 2) ។

**យោង** ៖ លិខិតចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់លោក វត្ត ញាតា ប្រធានគម្រោង Cambodia Communication Assistance Project (CCAP) នៃវិទ្យុអេប៊ីស៊ីអូស្ត្រាលី ។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងមហាផ្ទៃសូមជម្រាបជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង កំពង់ចាម កំពត និងខេត្តសៀមរាប ដែលជាខេត្តគោលដៅនៃគម្រោងជំនួយប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាដំណាក់កាលទី២ (Cambodia Communication Assistance Project Phase 2) ជ្រាបថា បន្ទាប់ពីគម្រោងជំនួយប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាដំណាក់កាលទី១ បានអនុវត្តបញ្ចប់ កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ កន្លងមក និងដោយយល់ឃើញពីសារសំខាន់នៃគម្រោងនេះក្នុងការជួយពង្រឹងគណនេយ្យភាពសង្គមនៅកម្ពុជា រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលីបានសម្រេចបន្តផ្តល់ជំនួយគាំទ្រគម្រោងនេះនៅដំណាក់កាលទី២ ហើយអនុស្សរណៈនៃការយោគយល់គ្នាក៏បានចុះហត្ថលេខារវាងក្រសួងព័ត៌មាន និងស្ថានទូតអូស្ត្រាលី នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥។

ជាក់ស្តែង សកម្មភាពគម្រោងនេះនឹងត្រូវអនុវត្តផ្ទាល់ដោយមន្ទីរព័ត៌មាននៅខេត្តគោលដៅចំនួន ៤ គឺខេត្តបាត់ដំបង កំពង់ចាម កំពត និងខេត្តសៀមរាប ប៉ុន្តែ ដើម្បីធានាឲ្យមានចូលរួម និងជួយសម្របសម្រួលពីរដ្ឋបាលថ្នាក់ក្រោមជាតិផងនោះ គម្រោងនេះក៏បានស្នើឲ្យមានអភិបាលរងខេត្តមួយរូបដែលទទួលបន្ទុកការងារព័ត៌មាន ឲ្យចូលរួមជាសមាជិកក្រុមពិគ្រោះយោបល់គម្រោង CCAP2 នេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាលខេត្ត មេត្តាពិនិត្យសម្រេចចាត់បញ្ជូនឯកឧត្តមអភិបាលរងមួយរូបដែលទទួលបន្ទុកការងារព័ត៌មាន មកក្រសួងមហាផ្ទៃ ត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ដើម្បីឲ្យចូលជាសមាជិកក្រុមពិគ្រោះយោបល់សម្រាប់ គម្រោងជំនួយប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាដំណាក់កាលទី២ តាមការស្នើសុំរបស់វិទ្យុអេប៊ីស៊ីអូស្ត្រាលី។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

**រដ្ឋលេខាធិការ**

**សក់ សេដ្ឋា**

**ចម្លងជូន**
- លេខាធិការដ្ឋាន គ.ជ.អ.ប
- អគ្គនាយកដ្ឋានរដ្ឋបាល
  (ដើម្បីជូនជ្រាប)
- ឯកសារ កាលប្បវត្តិ